ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ០១៥ សហវ.ហក

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

# សារាចរណែនាំ

## ស្តីពីការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ

**យោងតាម :**

- អនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋទៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- សារាចរណែនាំលេខ ០០៥ សហវ-ហ-សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- ផែនការសកម្មភាព ៦.៣ ស្តីពីការកាត់បន្ថយនូវដំណាក់កាលមិនចាំបាច់មួយចំនួននៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈក្នុងក្របខ័ណ្ឌអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំ ស្តីពីការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ ដោយធ្វើការបញ្ចេញអាណត្តិ ដោយពុំចាំបាច់ធ្វើការធានាចំណាយជាមុន ក្នុងគោលបំណងបង្កើនលទ្ធភាពឱ្យអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ ដើម្បីចំណាយថវិការបស់ខ្លួនទៅតាមឥណទានដែលបានអនុម័ត ។ ការកាត់បន្ថយនីតិវិធីនេះ សំរាប់តែមុខចំណាយមួយចំនួនដូចខាងក្រោម ÷

១/ <u>ចំណាយដែលមិនតម្រូវអោយអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងមានរបបកំណត់ច្បាស់លាស់ :</u>

- ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស
- ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស សំរាប់តែប្រាក់ហោប៉ៅ និងពន្ធព្រលានយន្តហោះ ឬទូទាត់សោហ៊ុយក្រៅប្រទេសដែលត្រូវផ្តល់ជាប្រាក់រៀលក្រោយពេលគណៈប្រតិភូត្រឡប់មកពីបរទេសវិញ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

- ចំណាយមានលក្ខណៈជាប្រក្រតីដែលមានវិក័យប័ត្រ ដូចជាចំណាយទូទាត់ថ្លៃប្រើប្រាស់អគ្គីសនី-ទឹក ទូរសព្ទ័ និងទូរសាររបស់រដ្ឋ
- ចំណាយទូទាត់ថ្លៃឈ្នួលសំរាប់អនុវត្តកិច្ចសន្យា ដូចជាថ្លៃឈ្នួលអគារស្នាក់ការ ឃ្លាំងសំភារៈ ថ្លៃឈ្នួលដឹកបញ្ជើប្រៃសណីយ៍ ។ល។
- ចំណាយបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ
- ចំណាយប្រជុំ សិក្ខាសាលា និងសន្និសិទដែលមានរបបកំណត់
- សោហ៊ុយសិក្សាពិសោធន៍ដែលមានរបបកំណត់
- សោហ៊ុយពិធីបុណ្យជាតិ ឬបុណ្យប្រពៃណីដែលមានរបបកំណត់
- ចំណាយបង់វិភាគទានដល់អង្គការអន្តរជាតិ
- ចំណាយឧបត្ថម្ភមន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូនដែលមានរបបកំណត់
- ចំណាយឧបត្ថម្ភមរណៈភាព
- ចំណាយឧបត្ថម្ភម្តងគត់ជូននិវត្តជន
- ចំណាយឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ
- ចំណាយឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ
- ចំណាយអាហាររូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស និងក្រៅប្រទេស
- ចំណាយឧបត្ថម្ភមណ្ឌលកុមារកំព្រា ។

*២/ចំណាយសំរាប់បណ្តាស្ថានទូត និងស្ថានអគ្គកុងស៊ុល នៅក្រៅប្រទេសនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ*

មុខចំណាយទាំងអស់នេះមានដូចខាងក្រោម ÷

- ចំណាយប្រាក់បៀវត្សមន្ត្រីការទូត
- ចំណាយថ្លៃឈ្នួលស្ថានទូត និងផ្ទះមន្ត្រីការទូត
- ចំណាយដំណើរការទូទៅរបស់ស្ថានទូត និងស្ថានអគ្គកុងស៊ុល

*៣/កិច្ចដំណើរការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុ*

ចំណាយចរិកាចរន្តដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើ ក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាល ត្រូវលើកសំណើសុំមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញកិច្ច) ដោយមានភ្ជាប់មកជាមួយ សក្ខីបត្រចំណាយ លិខិតយុត្តិការពាក់ពន្ធ័ច្បាស់លាស់ ព្រមទាំងអាណត្តិបើកប្រាក់ ដើម្បីជាមូលដ្ឋាននៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ ។

ទទួលបានសារាចរណែនាំនេះ សូមសម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា រតនាគារជាតិ និងអង្គភាពពាក់ពន្ធ័ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

__កន្លែងទទួល__

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង ស្ថាប័ន "នៅរដ្ឋបាលកណ្តាល"
- អង្គភាពពាក់ពន្ធ័ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីអនុវត្ត "
- ឯកសារ និងកាលប្បវត្តិ